គណៈកម្មាធិការ ព្រំដែន កម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
 គ.ព.ក CFC-CBC
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY
CFC-CBC 01102012K

## ហ៊ុន សែន បានចុះ កិច្ចព្រមព្រៀង ព្រំដែន រវាង កម្ពុជា និង វៀតណាម ដោយ របៀប ណា ?

*ដកស្រង់ពីសៀវភៅ* Evan R. GOTTESMAN, **Cambodia After the Khmer Rouge. Inside the politics of nation building,** Yale University Press, New Haven, CT, USA, November 2002, pp 209-211.

# ព្រំដែន
## *ឬ*
# «តម្លៃ នៃ អំណាច ក្នុង សម័យ សាធារណរដ្ឋ ប្រជាមានិត កម្ពុជា»

នៅក្នុងសម័យ សាធារណរដ្ឋប្រជាមានិតកម្ពុជា (ស.ប.ក. ) ភារៈកិច្ចមួយដ៏លំបាករបស់ ហ៊ុន សែន គឺការដឹកនាំក្រសួងរបស់គាត់ ក្នុងការចរចារព្រំដែនភាគខាងកើត ជាមួយប្រទេសយួន។ អ្នកទាំងឡាយ ដែលមានការមន្ទិលសង្ស័យ ថា យួនបានឆ្លៀតយកចំណេញ ដោយច្បិចយកដីខ្មែរ ខណៈដែលកងទ័ពខ្លួន កំពុងឈ្លានពាន កាន់កាប់ប្រទេសកម្ពុជា បានមកពពាក់ពពូនគ្នានៅ តាមជុំវិនានាតាមបណ្ដោយព្រំដែន។ ជនភៀសខ្លួន ជាពិសេសអ្នកមកពីខេត្តភាគខាងកើត បានលើកឡើងថា បង្គោលព្រំដែន ត្រូវបានគេបង្គិតចូល មកក្នុងដីខ្មែរ។ ដើម្បីបិទបាំង និងឆ្លើយតប ទៅនឹងការចោទប្រកាន់ ដែលថាប្រទេសយួនមានបំណងលេបប្រទេសកម្ពុជា និងដើម្បីដោះស្រាយ នូវបញ្ហា ដែលមានសល់ តាំងពីសម័យកម្ពុជាប្រជាធិបតេយ្យ ប្រទេសយួនបានប្រើល្បិច ខិតខំគ្រប់មធ្យោបាយ ដើម្បីធ្វើឱយមានកិច្ចព្រមព្រៀងព្រំដែន ជាមួយ ស.ប.ក.។ គឺជាការសំខាន់ណាស់ សម្រាប់អ្នកដឹកនាំក្រុងហាណូយ ហើយដើម្បីបង្ហាញឱយមតិសាធារណជន មើលឃើញថា ប្រទេសទាំងពីរ មានទំនាក់ទំនងទ្វេភាគីជាធម្មតា យួនត្រូវការអ្នកដឹកនាំខ្មែរ ដែលអាចទទួលយក និងការពារកិច្ចព្រមព្រៀងនោះ ។

ព្រំដែនសមុទ្រ ជាប្រធានបទ ដែលបានធ្វើឱយរលាយ នូវទំនាក់ទំនងរវាងប្រទេសយួន និងកម្ពុជាប្រជាធិបតេយ្យ នៅឆ្នាំ១៩៧៦ គឺជាបញ្ហាដែលត្រូវដោះស្រាយមុនគេ ។ កិច្ចព្រមព្រៀងមួយនាខែកក្កដា ឆ្នាំ១៩៨២ ដែលបានសម្រេចដោយ ហ៊ុន សែន ជាមួយរដ្ឋមន្ត្រីការបរទេសយួន ង្វៀន កូថាច់ បានបញ្ចូលឱយមានការទទួលស្គាល់ នូវអ្វីដែលគេហៅថា ខ្សែបន្ទាត់ប្រេវីយ៉េ ដែលជាខ្សែបន្ទាត់មួយ ដែលបានគូសនៅឆ្នាំ១៩៣៩ ដោយអាជ្ញាធរអាណានិគមបារាំង ដើម្បីសម្រួល ដល់កិច្ចការរដ្ឋបាល នាពេលនោះ តែមិនមែនជាព្រំសីមា បែងចែកអធិបតេយ្យភាពនោះទេ ។ មូលដ្ឋាននៃកិច្ចព្រមព្រៀង រវាង សីហនុ និង រណសិរ្សរំដោះជាតិ (*វៀតកុង*) បានបង្ហាញនៅក្នុងអារម្មណ៍ខ្មែរភាគច្រើនថា ការគូសខ្សែបន្ទាត់ប្រេវីយ៉េ ធ្វើឡើង ដោយហុចអំណោយផល ដល់ប្រទេសយួន (ខ្សែ

C/O M. SEAN - 8, Ave du Golf 77600 Bussy St Georges France - http://www.cfcambodge.org
Téléphone : +33(0)607 955 366 - Fax : +33(0)160 951 281 - Email : secretariat@cfcambodge.org

បន្ទាត់ប្រេវីយេ បានគូសចេញពីឆ្នេរឆ្ពោះទៅទិសខាងលិច ដោយបញ្ចូលទៅឱយយួន នូវកោះត្រល់ ដែលនៅជិតបង្កើយ ទិសខាងត្បូងនៃខេត្តកំពត)។ ហោ ណាំហុង ដែលជាអ្នកការទូត សម័យសីហនុ ហើយដែលធ្លាប់ជារដ្ឋទូតនៃស.ប.ក ប្រចាំសហភាពសូវៀត នាឆ្នាំ១៩៨២ ឋិតក្នុងចំណោមអ្នកដែលមិនពេញចិត្ត នឹងកិច្ចព្រមព្រៀងនោះ។ ជាច្រើនឆ្នាំក្រោយមក នៅពេលដែលគាត់បានក្លាយ ជារដ្ឋមន្ត្រីក្រសួងការបរទេស គាត់បានលើកឡើងថា «តាមពិត បន្ទាត់ប្រេវីយេ មិនមែនជាព្រំដែនទេ។ តាមពិតតំបន់នោះ ជារបស់យើង តាំងពីសម័យបារាំងកាន់កាប់ រហូតដល់សព្វថ្ងៃ ប៉ុន្តែដោយការព្រងើយកន្តើយរបស់យើង (ការខ្ជិល) ពួកយួនបានយកធ្វើ ជារបស់គេ ហើយការព្រងើយកន្តើយរបស់យើង ដែលមិនទាមទារ ធ្វើឱយយួនពេញចិត្តជាខ្លាំង»។

កិច្ចព្រមព្រៀងឆ្នាំ១៩៨២ ក៏បានគ្របលើ «ដែនទឹកប្រវត្តិសាស្ត្រ» ដែលស្ថិតនៅកាន់តែជិតមកខាងឆ្នេររបស់ខ្មែរ ។ ក្រិត្យទាំងឡាយដែលបានចេញដោយស.ប.ក. ក្នុងពេលចុះហត្ថលេខា បានបញ្ជាក់ថាប្រទេសយួនអាចប្រើប្រាស ដែនទឹកទាំងនោះ តែក្នុងករណីការពារតែប៉ុណ្ណោះ ចំណែកប្រទេសខ្មែររក្សាសិទ្ធ លើធនធានធម្មជាតិ នៅខ្ពង់រាបបាតសមុទ្រ ។ កិច្ចព្រមព្រៀងនោះ ហាក់ដូចជាមានភាពមិនច្បាស់លាស់ ដោយបានបញ្ជាក់ថា ចំពោះធនធានធម្មជាតិ ភាគីទាំងពីរត្រូវតែធ្វើសហប្រតិបត្តការ ហើយ «រាល់សេចក្តីសម្រេចណាមួយ ត្រូវតែធ្វើឡើងរួមគ្នា» (ជាច្រើនឆ្នាំក្រោយមក នៅពេលដែលមានការបោះឆ្នោត ដែលរៀបចំដោយ អ.ស.ប. ប្រទេសខ្មែរ និង យួន មានការមិនចុះសម្រុងគ្នា លើការរុករករ៉ែប្រេងកាត នៅបាតសមុទ្រ) ។ កិច្ចព្រមព្រៀង ក៏បានបញ្ជាក់នៅលើចំណុចមួយទៀត អនុញ្ញាត្តឱយ « អ្នកដែលរស់នៅក្នុងតំបន់ បន្តប្រកបអាជីវកម្មនេសាទ និងរុករកភោគផលក្នុងតំបន់សមុទ្រ តាមទម្លាប់ដែលមានមករហូតដល់សព្វថ្ងៃ » ។ ចំណុចនេះអាចបង្ករឱយមានវិវាទយ៉ាងធ្ងន់ធ្ងរ នៅពេលដែលកងឯកភាពទ័ពយួន បានចូលមកនេសាទ មិនត្រឹមតែក្នុង «ដែនទឹកប្រវត្តិសាស្ត្រ» ប៉ុន្តែបានចូលមកក្នុងដែនសមុទ្រខ្មែរ ។ ចំពោះសកម្មភាពនេសាទខុសច្បាប់ របស់កងប្រដាប់អាវុធយួននោះ មន្ត្រីនៅក្រសួងការបរទេស បានតវ៉ាជាច្រើនដងទៅ ហ៊ុន សែន ប៉ុន្តែអ្វីដែលបានកត់ត្រា នៅក្នុងកំណត់ហេតុអង្គប្រជុំ បានបញ្ជាក់ថា ហ៊ុន សែន បានត្រឹមតែស្តាប់ ហើយនៅស្ងៀម ។

នៅឆ្នាំ១៩៨៣ ហ៊ុន សែន បានចុះហត្ថលេខាមួយ ស្តីពីព្រំដែនគោក ជាមួយប្រទេសយួន ដោយយកផែនទី ដែលទទួលស្គាល់ទាំងសង ខាងតាំងពីឆ្នាំ១៩៥៤ជាមូលដ្ឋាន ។ លើកនេះក៏ដូចជាលើកមុនៗ គឺនិយាយតែពីភាពលំអិត និងចំណុចដែលត្រូវបោះបង្គោល ។ បន្ទាប់ពីបានជ្រើសរើស មន្ត្រីនៅក្រសួងការបរទេស ដែលត្រូវចូលរួម ក្នុងគណកម្មការចំរុះ ដើម្បីកំណត់ព្រំដែន ជាមួយប្រទេសយួន ហ៊ុន សែន និងទីប្រឹក្សាយួននៅក្រសួងការបរទេស បានណែនាំទិសដៅ នៃកិច្ចចរចារ យ៉ាងយកចិត្តទុកដាក់ ។ ឌិត មន្នី ដែលជាប្រធាន នៃគណកម្មការចរចារ បានត្រូវបញ្ជូនទៅ«សិក្សា»នៅទីក្រុងហាណូយ ដោយមិនមានការកំណត់មុខការ និងពេលវេលា ហើយត្រូវបានជំនួស ជាបណ្តោះអាសន្ន ដោយអតីតរដ្ឋទូតប្រចាំប្រទេសយួន ជាអនុរដ្ឋមន្ត្រីការបរទេស គង់ គាំ (សព្វថ្ងៃជាអនុប្រធាន នៃគណបក្សសម រង្ស៊ី)។ នៅពេលប្រជុំលើកទីមួយ នៃគណកម្មការ ទីប្រឹក្សាយួនម្នាក់ ដែលគេស្គាល់ថាឈ្មោះ «ទុន» បានពន្យល់ទៅមន្ត្រីខ្មែរ នូវអ្វីដែលត្រូវធ្វើ គាត់បាន

បញ្ជាក់ ថា «ក្នុងការចរចារ កម្ពុជាត្រូវប្រកាន់គោលជំហរជាត្រី: គឺមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តការណ៍ »។ ទុន ថែមទាំងបានសង្កត់ធ្ងន់ ការរក្សាការសម្ងាត់ ថា « កិច្ចការរបស់យើង ពីពេលនេះ ទៅអនាគត គឺត្រូវរក្សាការសម្ងាត់ កុំឱយមានការបែកធ្លាយឱយសោះ» ។ ថ្វីត្បិតតែមាន ការទាមទារពីខាងខ្មែរ ទាក់ទងទៅនឹងការខ្វះខាតថវិកា និងសម្ភារៈចាំបាច់ផ្សេងៗ ទុន បានបង្ខំ ឱយរៀបចំធ្វើកិច្ចការយ៉ាងប្រញាប់ ដើម្បីការចរចារនាពេលខាងមុខ «បើប្រៀបធៀបទៅខាងភាគីវៀតណាម កិច្ចការរបស់យើង គឺយឺតជាងគេបួនខែ ។ ខ្ញុំសូមជំរាបអង្គប្រជុំថា តាមទស្សនៈរបស់សមមិត្តរដ្ឋមន្ត្រី ហ៊ុន សែន ទាក់ទងទៅនឹងកិច្ចការនោះ ខាងភាគីកម្ពុជាត្រូវបំព្រួញ ឬកាត់បន្ថយ ពេលវេលាប្រជុំខ្លះ»។ ពីរខែក្រោយមក នៅក្នុងអង្គប្រជុំមួយ ដោយមានការរៀបចំជាស្រេច ដោយទីប្រឹក្សាយួន ហ៊ុន សែន បានអួតអាងពិការរីកចំរើន ពិកិច្ចការរបស់គណកម្មការ បើទោះជា សមាជិកនៃគណកម្មការខាងខ្មែរ បានលើកឡើង ពីកង្វះខាតផ្នែកថវិកា ដើម្បីចុះទៅតាមទីកន្លែង និងការខ្វះខាតសម្ភារៈទំនើប ដើម្បីធ្វើការវាស់វែង ។

នៅឆ្នាំ១៩៨៥ ក្រោយពេលបានឡើងជារដ្ឋមន្ត្រីទីមួយ ហ៊ុន សែន បានពង្រឹងការត្រួតត្រា របស់គាត់ថែមទៀត ក្នុងជួរគណរដ្ឋមន្ត្រី លើបញ្ហាព្រំដែន ។ នៅចុងឆ្នាំ១៩៨៥ដដែល គាត់បានសម្រេចជាផ្តាច់ព្រាត់ លើសន្ធិសញ្ញាព្រំដែនគោក ដែលគាត់បានការពារ និងពន្យល់ដល់អ្នកដែលនៅមានចិត្តរារែក ទាំងក្នុងជួររដ្ឋាភិបាល ទាំងនៅឯសភាជាតិ ។ គេនៅចាំបានថា ក្នុងកិច្ចប្រជុំមួយ នៃក្រុមប្រឹក្សារដ្ឋ ហ៊ុន សែន បានសារភាពថា ពិតជាមានការសម្រុះសម្រួលខ្លះ ដែលធ្វើឡើង ដោយភាគីខ្មែរ រួមទាំងការប្រើប្រាសផែនទី ឆ្នាំ១៩២៤ ដែលមានហុចអំណោយផល ទៅខាងភាគីយួន ។ ហេតុការនោះ បានធ្វើឱយមានការឆ្លើយតបពី ហេង សំរិន ថា «ក្នុងសម័យអាណានិគម វៀតណាម និងខ្មែរបានធ្វើការត្រួតពិនិត្យ លើបញ្ហាព្រំដែន ជាមួយគ្នា ដោយបានធ្វើការបោះបង្គោលតាមចំណុចត្រឹមត្រូវ ប៉ុន្តែបច្ចុប្បន្ន ខាងវៀតណាមបានសើរើបោះជាថ្មី ដោយមិនបារម្ភថា ត្រូវបោះឱយចំកន្លែងត្រឹមត្រូវឬអត់»។ ចាន់ វ៉ែន ដែលទើបបានលើកឡើង អំពីការបាត់បង់ដី នៅខេត្តស្វាយរៀង បានបញ្ចប់ការពិភាក្សាគ្នា ដោយថ្លែងថា « ខ្ញុំសូមសមមិត្តរដ្ឋមន្ត្រីទី១ រៀបចំខ្លួន ដើម្បីធ្វើការបកស្រាយ ពន្យល់ដល់សមាជិកសភាជាតិ » ។

នេះហើយជា តម្លៃនៃអំណាច ក្នុងសម័យសាធារណរដ្ឋ ប្រជាមានិត កម្ពុជា ។ ក្នុងនាមជារដ្ឋមន្ត្រីការបរទេស ហ៊ុន សែន បានខំការពារកិច្ចព្រមព្រៀងព្រំដែន ជាមួយប្រទេសយួន ទាំងចំពោះមតិសាធារណអន្តរជាតិ ទាំងក្នុងជួររបបរបស់គាត់ ។ បើទោះជាមានការជេរស្តី ឬ ការតវ៉ាយ៉ាងណា ពីសំណាក់មន្ត្រី ឬអ្នកមុខអ្នកការនៅក្នុងក្រសួងរបស់គាត់ ក៏ហ៊ុន សែន នៅតែរុលទៅមុខ បង្ហាញដល់អ្នកដឹកនាំយួន ថាគាត់ហ៊ានទទួលការខុសត្រូវដោយផ្ទាល់ ចំពោះទិដ្ឋភាពដ៏អប្រជាប្រិយ៍ និងខាតបង់ប្រយោជន៍របស់រាស្ត្រ ដើម្បីទំនាក់ទំនងទ្វេភាគី រវាងគាត់និងយួន ។

*(ការបកប្រែ ពីឯកសារអង់គ្លេស ដោយគណកម្មាធិការព្រំដែនកម្ពុជា នៅប្រទេសបារាំង និងក្នុងពិភពលោក)*